## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ..០៣......ស.រ

# សារាចរ
# ស្តីពី
# ការចាត់តាំងខួបលើកទី៦៨ ទិវាកុមារអន្តរជាតិ ១ មិថុនា ខួបលើកទី១៦ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២ មិថុនា និងទិវាកុមារកម្ពុជា ឆ្នាំ២០១៧

ជារៀងរាល់ឆ្នាំព្រះរាជាណាចក្រកម្ពុជាតែងប្រារព្ធ**ទិវាកុមារអន្តរជាតិ ១មិថុនា ទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២ មិថុនា និងទិវាកុមារកម្ពុជា** ដើម្បីរំលឹកដល់ការអនុវត្តសិទ្ធិជាមូលដ្ឋានរបស់កុមារ និងបង្ហាញពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលចំពោះកុមារ ស្របតាមរដ្ឋធម្មនុញ្ញ អនុសញ្ញាស្តីពី សិទ្ធិកុមាររបស់អង្គការសហប្រជាជាតិ អនុសញ្ញាលេខ១៨២ របស់អង្គការពលកម្មអន្តរជាតិស្តីពីការហាមប្រាម និងសកម្មភាពបន្ទាន់សម្រាប់លុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ និងបទដ្ឋានជាតិ អន្តរជាតិស្តីពីសិទ្ធិកុមារផ្សេងៗទៀត។

ការប្រារព្ធទិវាកុមារអន្តរជាតិ ១ មិថុនា គឺដើម្បីរំលឹកនូវព្រឹត្តិការណ៍វិនាសកម្មរបស់ពួកហ្វាសស៊ីស អ៊ីត្លែរ ដែលបានកាប់សម្លាប់ស្ត្រី និងកុមារនៅភូមិលីឌីសេ ប្រទេសឆេក និងនៅភូមិអូរាឌូ ប្រទេសបារាំង ក្នុងអំឡុងឆ្នាំ ១៩៤២-១៩៤៤ នៃសង្គ្រាមលោកលើកទី២ និងបានរួមគ្នាទប់ស្កាត់អំពើហិង្សា ដើម្បីថែរក្សាសន្តិភាពពិភពលោក និងជំរុញការអនុវត្តសិទ្ធិកុមារនៅគ្រប់ប្រទេស។

ការប្រារព្ធទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២ មិថុនា គឺបង្កើនចលនាពិភពលោកប្រឆាំងពលកម្មកុមារ ដែលបានស្តែងឱ្យឃើញ តាមរយៈការផ្តល់សច្ចាប័នលើអនុសញ្ញាអង្គការពលកម្មអន្តរជាតិ លេខ១៨២ ស្តីពីការហាម-ប្រាមនិងសកម្មភាពបន្ទាន់សម្រាប់ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ និងអនុសញ្ញាលេខ១៣៨ ស្តីពីអាយុអប្បបរមាសម្រាប់ចូលធ្វើការដោយប្រទេសជាច្រើនលើពិភពលោក សំដៅទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារក្នុងទម្រង់ធ្ងន់ធ្ងរដូចជា ទាសករកុមារ ការជួញដូរកុមារ ពេស្យាចារកុមារ និងការប្រើប្រាស់កុមារក្នុងជម្លោះប្រដាប់អាវុធ និងក្នុងស្ថានភាពងាយរងគ្រោះ។ ទិវានេះ ក៏ដើម្បីបំផុសឱ្យមានការគាំទ្របន្ថែមពី រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍ សង្គមស៊ីវិល និងអ្នកពាក់ព័ន្ធដទៃទៀត។

ដោយឡែក ព្រះរាជាណាចក្រកម្ពុជាធ្លាប់បានទទួលរងនូវមហាវិនាសកម្មដ៏ធ្ងន់ធ្ងរ ដែលបង្កឡើងដោយរបបប្រល័យពូជសាសន៍ **ប៉ុល ពត** ដែលបានកាប់សម្លាប់ប្រជាជនរាប់លាននាក់ និងបំផ្លាញសង្គមជាតិខ្ទេចខ្ទីដល់ឫសគល់ ក្នុងនោះកុមារក៏ត្រូវទទួលរងនូវការកាប់សម្លាប់ ធ្វើទារុណកម្ម បង្ខំឱ្យធ្វើការជាទម្ងន់ បង្អត់អាហារ រស់នៅយ៉ាងលំបាកវេទនាដោយអយុត្តិធម៌។ ក្រោយថ្ងៃរំដោះ ៧ ខែមករា ឆ្នាំ១៩៧៩ សិទ្ធិរបស់ប្រជាពលរដ្ឋ

ក្នុងនោះរួមមាន សិទ្ធិកុមារផង ត្រូវបានការពារ និងលើកតម្កើង ដោយមានចែងយ៉ាងច្បាស់នៅក្នុងរដ្ឋធម្មនុញ្ញ កម្មវិធីនយោបាយ ផែនការ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល។

ដើម្បីជំរុញការអនុវត្តសិទ្ធិកុមារឱ្យកាន់តែល្អប្រសើរឡើងថែមទៀត ស្របតាមស្ថានភាពរបស់ប្រទេសកម្ពុជា រាជរដ្ឋាភិបាល សូមធ្វើការណែនាំចាត់តាំងខួបលើកទី៦៨ ទិវាកុមារអន្តរជាតិ ១ មិថុនា ខួបលើកទី១៦ ទិវាពិភព-លោកប្រឆាំងពលកម្មកុមារ ១២ មិថុនា និងទិវាកុមារកម្ពុជា ឆ្នាំ២០១៧នេះ ដូចតទៅ ៖

១.ប្រធានបទនៃការប្រារព្ធខួបលើកទី ៦៨ ទិវាកុមារអន្តរជាតិ ១ មិថុនា ទិវាកុមារកម្ពុជា និងខួបលើកទី១៦ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ គឺ *"លើកកម្ពស់ការចូលរួមរបស់កុមារ ដើម្បីអភិវឌ្ឍន៍សង្គម"* និង *"ការពារកុមារពីពលកម្មកុមារនៅក្នុងស្ថានភាពជម្លោះ និងគ្រោះមហន្តរាយ"*។

២.ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងអប់រំ យុវជន និងកីឡា គណៈកម្មការជាតិរៀបចំបុណ្យជាតិ អន្តរជាតិ សាលារាជធានីភ្នំពេញ និងស្ថាប័នពាក់ព័ន្ធ ត្រូវសហការរៀបចំមីទ្ទិញថ្នាក់ជាតិ និងរៀបចំកម្មវិធីកម្សាន្តផ្សេងៗសម្រាប់កុមារ នៅរាជធានីភ្នំពេញ។

៣.ក្រសួងព័ត៌មានត្រូវសហការជាមួយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ណែនាំប្រព័ន្ធឃោសនារដ្ឋ និងឯកជនឱ្យធ្វើការផ្សព្វផ្សាយដល់សង្គមជាតិទាំងមូលឱ្យបានជ្រួតជ្រាបពីប្រវត្តិនៃទិវាកុមារអន្តរជាតិ ១ មិថុនា និងទិវាកុមារកម្ពុជា រួមទាំងទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២ មិថុនា ផងដែរ។

៤.គ្រប់ក្រសួងស្ថាប័ន រាជធានី ខេត្ត ត្រូវរៀបចំពិធីមីទ្ទិញ ពិធីជួបសំណេះសំណាលជាមួយកុមារ កម្មវិធីកម្សាន្តសប្បាយរបស់កុមារ នៅតាមក្រសួង ស្ថាប័ន រាជធានី ខេត្ត គ្រឹះស្ថានសិក្សារដ្ឋ ឯកជន អង្គការមិនមែនរដ្ឋាភិបាល និងគ្រប់មណ្ឌលកុមារកំព្រា នៅក្នុងមូលដ្ឋានរៀងៗខ្លួន។

៥.គ្រប់ក្រសួងស្ថាប័ន រាជធានី ខេត្ត គ្រឹះស្ថានសាធារណៈឯកជន ត្រូវរៀបចំចងបដាពាក្យស្លោក ដើម្បីអបអរសាទរខួបលើកទី៦៨ ទិវាកុមារអន្តរជាតិ ១ មិថុនា ខួបលើកទី១៦ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២ មិថុនា និងទិវាកុមារកម្ពុជា ឆ្នាំ២០១៧ នេះដូចតទៅ ៖

- ជយោ! ព្រះរាជាណាចក្រកម្ពុជា
- អបអរសាទរខួបលើកទី៦៨ ទិវាកុមារអន្តរជាតិ ១ មិថុនា ខួបលើកទី១៦ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២ មិថុនា និងទិវាកុមារកម្ពុជា ឆ្នាំ២០១៧
- លើកកម្ពស់ការចូលរួមរបស់កុមារ ដើម្បីអភិវឌ្ឍន៍សង្គម
- ការពារកុមារពីពលកម្មកុមារ នៅក្នុងស្ថានភាពជម្លោះ និងគ្រោះមហន្តរាយ
- អភិវឌ្ឍកុមារ ជាគ្រឹះនៃការអភិវឌ្ឍប្រទេសជាតិ
- យើងរួមគ្នា ដើម្បីលុបបំបាត់ពលកម្មកុមារ
- រួមគ្នាបញ្ឈប់ពលកម្មកុមារបម្រើការងារតាមផ្ទះ
- រួមគ្នាលុបបំបាត់ពលកម្មកុមារ ដើម្បីសិទ្ធិមនុស្ស និងយុត្តិធម៌សង្គម
- មិនត្រូវឱ្យកុមារធ្វើការងារប្រកបដោយគ្រោះថ្នាក់ និងបញ្ចប់ពលកម្មកុមារ
- យើងរួមគ្នាបង្កើនការយកចិត្តទុកដាក់លើកុមារ ដើម្បីអភិវឌ្ឍធនធានមនុស្ស និងគោលដៅឆ្ពោះទៅរកការបញ្ចប់ពលកម្មកុមារ
- កុមារ ជាទំពាំងស្នងឫស្សី ជាអនាគតរបស់ប្រទេសជាតិ

- កុមារបើល្អ កូនល្អ សិស្សល្អ មិត្តល្អ ជាអនាគតពលរដ្ឋល្អ

ទទួលបានសារាចរនេះ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ សាលារាជធានី ខេត្ត ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៧*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- សាលារាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ